**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣

**ថ្ងៃទី ០២-០៣ ខែមិថុនា ឆ្នាំ២០១០**

**ឯកឧត្តម ឈៀង យ៉ាណារ៉ា** អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ន/ក.អ.ក)

## សូចនាករតាមដានរួមគ្នា : គណនេយ្យភាពទ្វេទិសដោយផ្តោតលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍

- *សូមថ្លែងអំណរគុណជាថ្មីចំពោះ* ***ឯកឧត្តមឧបនាយករដ្ឋមន្ត្រី*** *ប្រធានវេទិកា !*
- *លោកជំទាវ និងឯកឧត្តម ជាសមាជិក សមាជិការាជរដ្ឋាភិបាល !*
- *លោកជំទាវ ឯកឧត្តម ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងតំណាងដៃគូអភិវឌ្ឍន៍ !*
- *លោកជំទាវ ឯកឧត្តម លោក លោកស្រី !*

១- ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម ប្រធានវេទិកា ដែលបានផ្តល់ឱកាសជាថ្មីម្តងទៀត និងសូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់បន្តរបស់លោកជំទាវ ឯកឧត្តម លោក លោកស្រី ។ នៅក្នុងរបៀបវារៈនេះ ខ្ញុំមានកិត្តិយសសូមធ្វើបទបង្ហាញអំពីសេចក្តីព្រាងតារាងសូចនាករតាមដានរួមគ្នា មុននឹងស្នើជូនអង្គវេទិកាអនុមតិ ។ ដូចឯកឧត្តម លោកជំទាវ លោក លោកស្រី បានជ្រាបរួចមកហើយថា សេចក្តីព្រាងតារាងសូចនាករតាមដានរួមគ្នានេះត្រូវបានពិភាក្សារួចម្តងហើយនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០ ។ ដូចនេះ ភារកិច្ចរបស់យើងនាថ្ងៃនេះ គឺការអនុមតិសេចក្តីព្រាងនៃសូចនាករតាមដានរួមគ្នាថ្មី ។ ទន្ទឹមនេះដែរ ខ្ញុំក៏សង្ឃឹមថា យើងអាចមានពិភាក្សាអំពីកិច្ចដំណើរការដែលបានអនុវត្តរហូតមកទល់បច្ចុប្បន្ននេះ និងទិសដៅការងារដែលយើងទាំងអស់គ្នាត្រូវអនុវត្តបន្តទៅថ្ងៃមុខ ដើម្បីផ្តល់ការគាំទ្រយ៉ាងពេញលេញដល់ការអនុវត្តន៍សូចនាករតាមដានរួមគ្នាទាំងនេះ ។

២- ឯកឧត្តម លោកជំទាវ លោក លោកស្រីមួយចំនួន ពិសេសខាងដៃគូអភិវឌ្ឍន៍ដែលបានបំពេញបេសកកម្មនៅកម្ពុជាក្រោយឆ្នាំ២០០៧ ប្រហែលមិនទាន់បានជ្រាបអំពីការវិវត្តន៍នានានៃការរៀបចំសូចនាករតាមដានរួមគ្នានៅឡើយ ។ នៅពេលដែលរាជរដ្ឋាភិបាលប្រារព្ធវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ ក្នុងឆ្នាំ២០០៧

ខ្ញុំបានផ្តល់ការសង្កេតរបស់ខ្ញុំថា យើងមិនទាន់បានអនុវត្តបណ្តាគោលការណ៍នានា ពិសេស គោលការណ៍ស្តីពី «គណនេយ្យភាពទ្វេទិស» ឱ្យបានពេញលេញនៅឡើយ ។

៣- ដោយផ្អែកលើរបាយការណ៍ស្តីពីសូចនាករតាមដានរួមគ្នា និងលទ្ធផលនៃកិច្ចប្រជុំពិភាក្សាក្នុងការពិនិត្យឡើងវិញនូវកិច្ចដំណើរការដែលបានប្រព្រឹត្តទៅកាលពីខែមេសាកន្លងមក ខ្ញុំមានសេចក្តីសោមនស្សសូមជម្រាបជូនអំពីវឌ្ឍនភាពជាច្រើនគួរឱ្យកត់សំគាល់របស់យើងទាំងអស់គ្នា ។ នៅលើសូចនាករតាមដានរួមគ្នាទាំងអស់ យើងបានពិនិត្យឃើញអំពីសក្ខីកម្មនៃ *«ការពិគ្រោះយោបល់រួមគ្នា ការកំណត់សកម្មភាពរួមគ្នា ការអនុវត្តន៍រួមគ្នា* និង *ការតាមដានរួមគ្នា»* ។ ខ្ញុំសូមស្វាគមន៍ និងកោតសរសើរចំពោះវឌ្ឍនភាពទាំងនេះ។

៤- បទបង្ហាញរបស់ខ្ញុំនាពេលនេះនឹងលើកបង្ហាញដោយសង្ខេប អំពីលទ្ធផលនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នាឆ្នាំ២០០៩-២០១០ ដែលត្រូវបានអនុមតិនៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ នាខែធ្នូ ឆ្នាំ២០០៨ ។ ហើយបន្ទាប់មក នឹងពិនិត្យឡើងវិញអំពីវឌ្ឍនភាពក្នុងការពង្រឹងកិច្ចដំណើរការរៀបចំសូចនាករទាំងនេះ មុននឹងអនុមតិសូចនាករតាមដានរួមគ្នាថ្មីនេះ ។

៥- របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០១០ ហើយបានពិភាក្សាគ្នាក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ កាលពីថ្ងៃទី២៩ខែមេសាឆ្នាំ២០១០ ។ ជាទូទៅ យើងសម្រេចបានវឌ្ឍនភាពគួរឱ្យលើកទឹកចិត្ត ដូចបានបង្ហាញក្នុងតារាង ។ នៅតាមវិស័យនានានៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ សូចនាករតាមដានរួមគ្នាត្រូវបានអនុវត្តយ៉ាងពេញលេញ និងមានវឌ្ឍនភាពគួរជាទីមោទនៈ ។ រីឯក្នុងវិស័យ ១ឬ២តែប៉ុណ្ណោះ ពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធ យើងប្រហែលជាត្រូវបន្តការពិភាក្សា និងការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីធានាថាសកម្មភាពអាទិភាពត្រូវបានអនុវត្ត ។ ប៉ុន្តែ ជារួម យើងពេញចិត្តចំពោះវឌ្ឍនភាពនេះ ។

៦- ពិសេសជាងនេះទៅទៀត យើងអាចមើលឱ្យបានវែងឆ្ងាយជាងលទ្ធផលដែលយើងសម្រេចបាន ដើម្បីពិចារណាអំពីគុណភាពនៃដំណើរការរៀបចំរបស់យើង ។ របាយការណ៍របស់ក្រុមការងារបច្ចេកទេសភាគច្រើនបានបង្ហាញយ៉ាងច្បាស់ ដូចដែលខ្ញុំបានជម្រាបជូនខាងដើមថា មានវឌ្ឍនភាពកាន់តែប្រសើរឡើងក្នុងការរៀបចំរួមគ្នានូវ « *សូចនាករតាមដានរួមគ្នា»* ។ ប៉ុន្តែ អ្វីដែលសំខាន់ជាងនេះគឺ ការរៀបចំសូចនាករទាំងនេះបានចាក់គ្រឹះយ៉ាងរឹងមាំទៅក្នុងយន្តការនៃការរៀបចំផែនការ និងតាមដានរបស់ក្រុមការបច្ចេកទេសចម្រុះ និងរបស់ក្រសួងនិងស្ថាប័នពាក់ព័ន្ធផងដែរ ។ ខ្ញុំជឿជាក់ថា ដំណើរការនេះត្រូវបានពង្រឹងបន្ថែមតាមរយៈការបង្កើនកិច្ចសហការនិងឥរិយាបថប្រកបដោយស្មារតីរបស់ដៃគូអភិវឌ្ឍន៍ផងដែរ ។ ខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អ្នកសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានចំណាយពេលវេលាសម្រាប់ចូលរួមក្នុងការងាររបស់ក្រុមការងារបច្ចេកទេស និងបានចូលរួមចំណែកពង្រឹងភាពជាដៃគូឱ្យកាន់តែមានភាពដ៏រឹងមាំបន្ថែមទៀត និងប្រកបដោយប្រសិទ្ធភាព ។ ខ្ញុំក៏ជឿជាក់ថា វឌ្ឍនភាពទាំងនេះនឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់បង្កើនលទ្ធផលធំធេងបន្ថែមទៀតនាពេលអនាគត ។

៧-	ដោយឈរលើគោលគំនិតនេះ ខ្ញុំសូមអនុញ្ញាត លោកជំទាវ ឯកឧត្តម លោកនិងលោកស្រី ដើម្បីជម្រាបជូនអង្គវេទិកាអំពីដំណើរការនៃការរៀបចំសូចនាករតាមដានរួមគ្នាសម្រាប់ឆ្នាំ២០១០-២០១១ ។

៨-	យើងបានឯកភាពគ្នានៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ ឆ្នាំ២០០៨ ថានឹងពិនិត្យឡើងវិញអំពីយន្តការ និងទម្រង់នៃសូចនាករតាមដានរួមគ្នា ដោយត្រូវផ្តោតលើលទ្ធផល តែត្រូវរក្សានូវគោលការណ៍«រួមគ្នា» និង«អភិក្រមនៃភាពជាដៃគូ» ដែលគោលការណ៍ដើមក្នុងការរៀបចំសូចនាករ ។

៩-	យើងបានសម្រេចការងារទាំងនេះដោយជោគជ័យគួរឱ្យកត់សំគាល់ ។ ដោយផ្អែកលើមូលដ្ឋាននៃ«ដំណើរការជម្រុញឱ្យមានលទ្ធផល» ការបណ្តុះបណ្តាល និងទម្រង់ថ្មីនៃសូចនាករតាមដានរួមគ្នា បានទទួលជោគជ័យ តាមរយៈការពង្រឹងសមត្ថភាពការងារដោយផ្តោតលើលទ្ធផលនៅតាមវិស័យជាច្រើន ។ យើងបានកែលំអទម្រង់នៃសូចនាករនេះ ដោយឆ្លុះបញ្ចាំងអំពី «ខ្សែសង្វាក់ធាតុចេញ និងលទ្ធផល» ព្រមទាំងបានរំលេចឱ្យកាន់តែច្បាស់បន្ថែមទៀតចំពោះតួនាទីនៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងតួនាទីរបស់ដៃគូអភិវឌ្ឍន៍ ។ ពិសេសជាងនេះទៀត យើងមានលទ្ធភាពបង្កើតសូចនាករតាមដាននេះ ដោយឈរលើសមត្ថភាពដែលមានស្រាប់ និងពង្រឹងបន្ថែមការផ្សារភ្ជាប់ទៅនឹងកិច្ចដំណើរការដោយផ្តោតលើលទ្ធផល ។

១០-	ដូចខ្ញុំបានជម្រាបជូនពីខាងដើម សូចនាករតាមដានរួមគ្នាកាន់តែមានចរិត *«រួមគ្នា»* និងបានផ្អែកលើគោលការណ៍ «គណនេយ្យភាពទ្វេទិស» ។ ដូចយើងបានពិភាក្សាក្នុងរបៀបវារៈមុននេះ ដោយយើងបានផ្តោតទៅលើ«លទ្ធផល» ខ្ញុំជឿជាក់ថា ការអនុវត្តន៍សូចនាករតាមដានរួមគ្នាថ្មីទាំងនេះ នឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការឈានទៅសម្រេចលទ្ធផលដែលរំពឹងទុក ប្រសិនបើយើងគោរពគោលការណ៍ទាំងឡាយបានម៉ត់ចត់ ។ ការបញ្ជាក់អំពី «ខ្សែសង្វាក់លទ្ធផលច្បាស់លាស់» និងការបញ្ចូលគោលការណ៍នៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ បានបង្ហាញអំពីសញ្ញាណវិជ្ជមានក្នុងការពង្រឹងភាពជាដៃគូរបស់យើងនាពេលអនាគត ។

*លោកជំទាវ ឯកឧត្តម លោក លោកស្រី*

១១-	ខ្ញុំសង្ឃឹមថា យើងមានឱកាសសម្រាប់ពិភាក្សាលើបញ្ហានានាដែលពាក់ព័ន្ធនឹងការអនុវត្តន៍សូចនាករក៏ដូចជាពិភាក្សាលើបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តន៍ មុននឹងយើងអនុមតិសូចនាករតាមដានរួមគ្នា ។

*សូមថ្លែងអំណរគុណ* ចំពោះការយកចិត្តទុកដាក់របស់*លោកជំទាវ ឯកឧត្តម លោក លោកស្រី !*